ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៧ អនក្រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើ មាត្រា៤ ចំណុច ៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រង តំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សំរេច

**ប្រការ ១.-**

បង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដែលមានទីតាំងស្ថិតនៅចន្លោះឃុំភ្លើងឆេះរទេះ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ និងឃុំកន្ទោក-ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានសមាសភាពដូច ខាងក្រោម :

| | |
|---|---|
| ១- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២- តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៣- តំណាងទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ៤- តំណាងនាយកដ្ឋានត្រួតពិនិត្យទំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

សមាជិករដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ ប្រធាន ។

**ប្រការ ២.-**

រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនេះ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម :

- ត្រួតពិនិត្យតាមមុខជំនាញសមត្ថកិច្ចចំពោះការចេញពី និងចូលមកនូវទំនិញ មធ្យោបាយ និងជនានុជន គ្រប់រូបរបស់តំបន់ ។ អនុវត្តការត្រួតពិនិត្យបែបបទគយ សំរាប់ការចេញ-ចូលទំនិញ និងសំរួលបែបបទរដ្ឋបាលដល់កិច្ចដំណើរការរបស់តំបន់ ជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ចជំនាញនានា របស់រាជរដ្ឋាភិបាល ។
- ត្រួតពិនិត្យការអនុវត្តន៍ការងាររបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ លើរាល់សកម្មភាពនៅក្នុងតំបន់ ដោយផ្អែកតាមគោលការណ៍ដែលបានកំណត់ ។
- ពិនិត្យលើសំណើសុំចុះបញ្ជីវិនិយោគ ពិនិត្យផ្តល់ជូននូវការលើកទឹកចិត្ត ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ វិញ្ញាបនប័ត្រប្រភពដើមទំនិញ ដែលស្នើឡើងដោយអ្នកវិនិយោគក្នុងតំបន់ ដើម្បីធ្វើការសំរេចជូនអ្នកវិនិយោគក្នុងតំបន់ នៅនឹងកន្លែង ។

www.pheakdeylaw.com

- ធ្វើការត្រួតពិនិត្យការងារសកម្មភាព តាមមុខជំនាញនៅក្នុងតំបន់ ។
- សហការជាមួយអ្នកអភិវឌ្ឍន៍តំបន់ ដោះស្រាយការងារដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។
- សំរួលរាល់បែបបទដែលពាក់ព័ន្ធឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព ។
- ធ្វើរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ឆមាស និងឆ្នាំ ពីសកម្មភាពរបស់តំបន់ជូនក្រសួង-ស្ថាប័នគ្រប់គ្រង គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង
- ធ្វើកិច្ចការផ្សេងៗទៀតក្នុងការសំរបសំរួលដោះស្រាយរាល់សំណើ របស់អ្នកវិនិយោគក្នុងតំបន់ពាក់ព័ន្ធទៅនឹងបណ្តាក្រសួង-ស្ថាប័ននានា របស់រាជរដ្ឋាភិបាល ។

**ប្រការ ៣.-**

គ្រប់តំណាងក្រសួង-ស្ថាប័ន ដែលបំពេញភារកិច្ចនៅក្នុងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដូចមានចែងក្នុងប្រការ១ត្រូវដំណើរការការងារទៅតាមនីតិវិធីនៃច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលក្រុងភ្នំពេញ អភិបាលខេត្តកណ្តាល និងក្រុមហ៊ុន ភ្នំពេញ អេស អ៊ី ហ្ស៊េត ខូអិលធីឌី មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ១០ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com